ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.............................................................

# សេចក្តីប្រកាសព័ត៌មាន

នៅព្រឹកថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣ នៅធនាគារជាតិនៃកម្ពុជា មានរៀបចំកិច្ចប្រជុំទ្វេភាគីរវាងគណៈកម្មការសេវាហិរញ្ញវត្ថុកូរ៉េ និងធនាគារជាតិនៃកម្ពុជា ក្រោមអធិបតីភាព **ឯកឧត្តម ជា ចាន់តូ** ទេសាភិបាលធនាគារជាតិនៃកម្ពុជា និង **ឯកឧត្តម Kyung Ho CHOO** អនុប្រធានគណៈកម្មការសេវាហិរញ្ញវត្ថុកូរ៉េ ក្នុងគោលបំណងរឹតចំណងកិច្ចសហប្រតិបត្តិការទ្វេភាគីលើការផ្តល់ជំនួយបច្ចេកទេស និងការត្រួតពិនិត្យវិស័យធនាគារនិងហិរញ្ញវត្ថុ ។

គណៈប្រតិភូទាំងពីរបានប្រជុំពិភាក្សា និងផ្លាស់ប្តូរយោបល់គ្នាអំពីស្ថានភាពបច្ចុប្បន្ននៃសេដ្ឋកិច្ចសកល ការរីកចម្រើនវិស័យហិរញ្ញវត្ថុរបស់កូរ៉េ ការអភិវឌ្ឍសេដ្ឋកិច្ច ហិរញ្ញវត្ថុនិងធនធានមនុស្សនៅកម្ពុជាព្រមទាំងវិធានការនានាដើម្បីរឹតចំណងកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូរវាងគណៈកម្មការសេវាហិរញ្ញវត្ថុកូរ៉េ និងធនាគារជាតិនៃកម្ពុជា និងពង្រីកចំណងមិត្តភាពរវាងប្រទេសទាំងពីរឲ្យកាន់តែមានភាពជិតស្និទ្ធ និងប្រសើរឡើងថែមទៀត ។

នេះជាកិច្ចប្រជុំដ៏មានសារៈសំខាន់ ព្រោះជាវេទិកាសម្រាប់ផ្លាស់ប្តូរព័ត៌មានថ្មីៗអំពីស្ថានភាពវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទាំងក្នុងនិងក្រៅប្រទេសទាំងពីរ និងពិភាក្សារកដំណោះស្រាយចំពោះបញ្ហាប្រឈមនានាបន្ថែមលើយន្តការថ្នាក់តំបន់ ក៏ដូចជាវេទិកាដែលផ្តល់ឱកាសដល់ភាគីទាំងពីរ ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការប្រកបដោយស្មារតីសាមគ្គីភាព និងភាតរភាពផងដែរ ។

ដោយយល់ឃើញពីផលប្រយោជន៍រួមនិងសេចក្តីត្រូវការចាំបាច់របស់ស្ថាប័ននៃប្រទេសទាំងពីរនៅពេលបច្ចុប្បន្ន និងទៅអនាគត ដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព ទើបធនាគារជាតិនៃកម្ពុជា និងគណៈកម្មការសេវាហិរញ្ញវត្ថុកូរ៉េ ប្រារព្ធពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នានេះឡើង ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីលើការផ្លាស់ប្តូរព័ត៌មាន និងជំនួយបច្ចេកទេស និងការងារត្រួតពិនិត្យវិស័យធនាគារនិងហិរញ្ញវត្ថុរវាងស្ថាប័នពីរ រួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព ។

ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧